ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

តុលាការកំពូល
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៣២
ចុះថ្ងៃទី២២-មិថុនា-
១៩៩៩
សាលដីកាលេខ: ២៦
ចុះថ្ងៃទី១៤-៦-២០០០

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៤ខែមិថុនាឆ្នាំ ២០០០ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅ៖

១-ឯកឧត្តម... ប្រធាន
២-លោក... ចៅក្រម
៣-លោក... ចៅក្រមរបាយការណ៍
៤-លោក... ចៅក្រម
៥-លោក... ចៅក្រម

ក្រឡាបញ្ជី
លោក...
តំណាងមហាអយ្យការ
ឯកឧត្តម...អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខលេខ៤៧ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ ១៩៩៩ របស់ឈ្មោះ...មេធាវីការពារជនជាប់ចោទ ដែលប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ១១៧ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧ

ឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល និងសំណុំរឿងព្រហ្មទណ្ឌលេខ៣២ ចុះថ្ងៃទី ខែមិថុនា ឆ្នាំ១៩៩៩ របស់តុលាការកំពូល។

ពីបទៈប៉ុនប៉ងធ្វើមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិទី៥ឃុំទ្រា ស្រុកក្រូចឆ្មា ខេត្តកំពង់ចាម កាលពីថ្ងៃទី ១៤-០១-៩៩ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-ជនជាប់ចោទឈ្មោះ **ហក** ភេទប្រុសអាយុ៣៨ឆ្នាំ ជាតិឥស្លាម កើតនៅភូមិទ្រាទី៣ ឃុំទ្រា ស្រុកក្រូចឆ្មា ខេត្តកំពង់ចាម របររកស៊ីលក់និងទិញគោកម្រិតវប្បធម៌ថ្នាក់ទី៤ មានទីលំនៅសព្វថ្ងៃ ភូមិទ្រា៣ ស្រុកក្រូចឆ្មា ខេត្តកំពង់ចាម ឪពុកឈ្មោះ...ម្តាយឈ្មោះ...ប្រពន្ធឈ្មោះ...មានកូន០៤នាក់។ ទោសពីមុនគ្មាន នៅក្រៅឃុំ។

-មានមេធាវីលោក...

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **ផម** ជាឪពុកជនរងគ្រោះឈ្មោះ... អាយុ៦៥ឆ្នាំជាតិខ្មែរឥស្លាម នៅភូមិទី៥ ឃុំទ្រា ស្រុកក្រូចឆ្មា ខេត្តកំពង់ចាម មុខរបរធ្វើស្រែចំការ។ឪពុកឈ្មោះ...ម្តាយឈ្មោះ...ប្រពន្ធឈ្មោះ.. មានកូន៨នាក់។

-មានមេធាវីលោក...

តាមបណ្តឹងសាទុក្ខលេខ៤៧ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៩ របស់លោក... ជាមេធាវីការពារជនជាប់ចោទ ដែលប្តឹងតវ៉ាដីកាព្រហ្មទណ្ឌលេខ១១៧ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល។

តាមពាក្យបណ្តឹង ចុះថ្ងៃទី១៨-០១-៩៩របស់ **ផម** ឪពុកជនរងគ្រោះប្តឹងពីឈ្មោះ...និងបក្សពួកប៉ុនប៉ងធ្វើមនុស្សឃាតលើរូបកូនខ្លួនឈ្មោះ**មស**។

ខ្លួនទាមទារជំងឺចិត្ត និងថ្នាំព្យាបាលចំនួន២០,០០០,០០០រៀល និងសុំឱ្យផ្តន្ទាទោសជនល្មើសតាមច្បាប់។

តាមពាក្យបណ្តឹង របស់ឈ្មោះ **សក** ចុះថ្ងៃទី០២-០២-៩៩ ប្តឹងពីឈ្មោះ **ជម** និងឈ្មោះ **ទស** ដែលបានបរិហាកេរ្តិ៍មកលើខ្លួន។ ដោយនិយាយថាខ្លួនលួចបាញ់សម្លាប់ ឈ្មោះ **មស** កាលពីថ្ងៃទី១៥-០២-៩៩ ខ្លួនទារជំងឺចិត្ត ២០,០០០ ដុល្លាអាមេរិក និងសុំឱ្យផ្តន្ទាជនល្មើសតាមច្បាប់។

-បានឃើញដីកាឃុំខ្លួនលេខ៦៩ព្រទ ចុះថ្ងៃទី០៩-០៤-៩៩ និងដីកាដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្នលេខ៦៩ព្រទ ចុះថ្ងៃទី០១-០៥-១៩៩៩ របស់ចៅក្រមស៊ើបអង្កេតខេត្តកំពង់ចាម។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៤៥ ចុះថ្ងៃទី០១-០៤-១៩៩៩ របស់ឈ្មោះ **មស** ដែលប្តឹងតវ៉ាពីដីកាសម្រេចដោះលែងឱ្យជនល្មើសនៅក្រៅឃុំបណ្តោះអាសន្នលេខ៦៩ព្រទ ចុះថ្ងៃទី០៩-០៤-៩៩ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកំពង់ចាម។

-បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា៖ ដើម្បីធានាដល់នីតិវិធីតុលាការសុំឱ្យការចេញដីកាចាប់ខ្លួនជន ដែលត្រូវចោទមកឃុំជាបណ្តោះអាសន្ន។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១១៧ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ដែលបានសម្រេច៖

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០១-០៥-៩៩របស់ឈ្មោះ **មស** ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់។

២-បដិសេធដីកាសម្រេចឱ្យជនជាប់ចោទ នៅក្រៅឃុំបណ្តោះអាសន្ន លេខ៦៩ព្រទ ចុះថ្ងៃទី០១-០៤-៩៩ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្ត កំពង់ចាម ចោលជាអសារបង់។

៣-បង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ **ហម** ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិឥស្លាម នាពេលសវនាការមហាម៉ាត់មុខរបរលក់ទិញគោ ទីលំនៅសព្វថ្ងៃ ភូមិទ្រាទី៣ ស្រុកក្រូចឆ្មា ខេត្តកំពង់ចាម កម្រិតវប្បធម៌ថ្នាក់ទី៤ថ្មី។ឪពុកឈ្មោះ ...ម្តាយឈ្មោះ...ប្រពន្ធឈ្មោះ...មានកូន០៤នាក់ មកដាក់ក្នុងមន្ទីរឃុំឃាំង ដើម្បីឃុំខ្លួនបណ្តោះអាសន្នបន្តទៀត។

៤-សាលដីកានេះ មានអនុភាពអនុវត្តភ្លាមៗ ទោះជាមានបណ្តឹងសាទុក្ខក៏ដោយ។

-សាលដីកានេះជំនុំជម្រះ និង ប្រកាសជាសាធារណៈចំពោះមុខជនរងគ្រោះ និងមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ៤៧ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៩ របស់ឈ្មោះ...ជាមេធាវី ការពារជនជាប់ចោទ ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ១១៧ ចុះថ្ងៃទី១៩-ខែឧសភា ឆ្នាំ១៩៩៩របស់សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល។

-បានឃើញសារណាចុះថ្ងៃទី១៩ខែកញ្ញាឆ្នាំ១៩៩៩របស់ឈ្មោះ **ហក** គឺជាជនជាប់ចោទធ្វើឡើងក្នុងកំណត់ច្បាប់។

-បានឃើញសារណាតប ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៩៩ របស់ឈ្មោះ **មស** ជាចុងបណ្តឹងសាទុក្ខធ្វើឡើងក្នុងកំណត់ច្បាប់។

-បានស្តាប់សារតាជាតិរបស់ជនជាប់ចោទឈ្មោះ **ហក** ដែលមានមេធាវីជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជម្រះ។

-បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមអយ្យការអមតុលាការកំពូលថា៖ ការដែលសម្រេចឱ្យជនជាប់ចោទ នៅក្រៅឃុំ ឃើញថាមិនអាចធានាដល់ការស៊ើបអង្កេតរបស់តុលាការ ពុំឃើញមានភស្តុតាងណាមួយដោះបន្ទុកយកជាការបានឡើយ។ ដូច្នេះសុំតុលាការ ពិចារណាឱ្យបានច្បាស់ក្នុងការឱ្យជនជាប់ចោទនៅក្រៅឃុំព្រោះរឿងនេះជារឿងឧក្រិដ្ឋ ហើយការសម្រេចឱ្យនៅក្រៅឃុំជាឧបសគ្គដល់ការស៊ើបអង្កេត។ សូមតម្កល់សាលដីកាសាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល។

-បានស្តាប់សារណារបស់ជនជាប់ចោទឈ្មោះ **ហក** មានមេធាវីជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជម្រះ។

-បានស្តាប់អំណានសារណាតបរបស់ជនរងគ្រោះឬ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **មស** ចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជម្រះ។

-បានស្តាប់សេចក្តីសន្និដ្ឋាន របស់លោក...ម្ចាស់បណ្តឹងសាទុក្ខ ជាមេធាវីការពារឱ្យជនជាប់ចោទ ឈ្មោះ **សក** នៅពេលជំនុំជម្រះថា៖ កូនក្តីខ្ញុំមិនបានបាញ់មនុស្ស ដូចលោក **មស** ចោទប្រកាន់ឡើយ ព្រោះថ្ងៃកើតហេតុនោះកូនក្តីខ្ញុំក៏ត្រូវជនឈ្មោះ **ម** ដែលលួចបាញ់ តែកូនក្តីខ្ញុំគេចផុតបែរជាគេមកចោទកូនក្តីខ្ញុំបាញ់ **មស** ទៅវិញ នេះមិនមែនជាការពិតទេ ដែលថាកូនក្តីខ្ញុំបាញ់ **ស** នោះម្យ៉ាងទៀតក្រោយកើតហេតុ សម្តីរបស់ **មស** បានផ្តាំថាកុំឱ្យ **ក** ប្តឹងផ្តល់អី រឿងនេះចប់ត្រឹមនឹងទៅ នេះរឹតតែបញ្ជាក់ថា កូនក្តីខ្ញុំជាអ្នករងគ្រោះបែរជាចោទថាជនល្មើសទៅវិញ។ ពិសេសទៅទៀត រឿងហេតុកើតឡើងនៅថ្ងៃទី១៥-០១-

៩៩ លុះដល់ថ្ងៃទី០៩-០៤-៩៩ សមត្ថកិច្ចមកចាប់កូនក្តីខ្ញុំ ចោទ ថាជាអ្នកបាញ់ **មស** ទៅវិញ។

សូមតុលាការពិចារណាមើល បើកូនក្តីខ្ញុំជាអ្នកប្រព្រឹត្តនោះ ក្នុងរយៈពេល០៤ខែនេះកូនក្តីខ្ញុំដឹងគេបាញ់ហើយ តែកូនក្តីខ្ញុំជាអ្នករងគ្រោះ ហើយប្តឹងទៅសមត្ថកិច្ច នៅថ្ងៃទី១៥-០១-៩៩ នៅថ្ងៃកើតហេតុតែម្តង លុះដល់ថ្ងៃទី១៨-០៥-៩៩ ទើបលោក **ជម** ជាឪពុករបស់ **មស** ប្តឹងបកវិញ ដូច្នេះឃើញថាកូនក្តីខ្ញុំមិនមែនជាជនល្មើសទេ។

សូមលោកតុលាការឱ្យកូនក្តីខ្ញុំនៅក្រៅឃុំបណ្តោះអាសន្ន ព្រោះកូនក្តីខ្ញុំជាមេបន្ទុកក្នុងគ្រួសារ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែម នាពេលសវនាការរបស់តំណាងមអយ្យការអមតុលាការកំពូលថា៖ មិនអាចធានាឱ្យជនជាប់ចោទ នៅក្រៅឃុំបណ្តោះអាសន្នបានទេ ព្រោះគ្មានភស្តុតាងណាមួយដែលបញ្ជាក់ឱ្យច្បាស់លាស់ថា ជនជាប់ចោទគ្មានកំហុសឡើយ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណាការពារ របស់ម្ចាស់បណ្តឹងសាទុក្ខ សារណាឆ្លើយតបរបស់ចុងបណ្តឹងសាទុក្ខ និងសេចក្តីសន្និដ្ឋានការពារ របស់មេធាវីម្ចាស់បណ្តឹងសាទុក្ខ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៤៧ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៩ របស់លោក **ឡគស** មេធាវីការពារ ឱ្យជនជាប់ចោទឈ្មោះ **ហក** ធ្វើ

ឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី។

-យល់ឃើញថាបទល្មើសនេះ ជាបទមនុស្សឃាតគិតទុកជាមុន ដែលមានជនដៃដល់ និងគូកន ហើយជនជាប់ចោទ **ហក** និងការស៊ើបអង្កេតពុំទាន់ឃើញភស្តុតាងណាមួយដោះបន្ទុកយកជាការបានឡើយ។ ដូច្នេះ ការឱ្យជនជាប់ចោទនៅក្រៅឃុំ អាចធ្វើឱ្យប៉ះពាល់ដល់ការស៊ើបអង្កេតរបស់តុលាការ។

-យល់ឃើញថា ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសារណាការពាររឿងក្តី របស់ខ្លួនជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែមិនបានមកចូលរួមនាពេលវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជម្រះរឿងនេះ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ១១៧ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ នឹងគតិច្បាប់ហើយ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្តឹងសាទុក្ខលេខ៤៧ ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៩៩ របស់លោក...មេធាវីជនជាប់ចោទ ទុកត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹងគតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ១១៧ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ៣២ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ ១៩៩៩ របស់តុលាការកំពូលទៅតុលាការខេត្តកំពង់ចាម ដើម្បីចាត់ការតាមច្បាប់។

៤-សាលដីកានេះ ប្រកាសទាសវនាការជាសាធារណៈ នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០០។